ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ករណីឆបោកបុគ្គលិករដ្ឋបាល ឬតំណាង សហគ្រាស គ្រឹះស្ថាន ឬសាមីកម្មករនិយោជិត ឱ្យប្រើមធ្យោបាយក្លែងក្លាយក្នុងការទូទាត់ថ្លៃសេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីកម្មករនិយោជិត ឱ្យបានជ្រាបថា នាពេលថ្មីៗនេះមានជនអនាមិកបានបង្កើតគណនីតេឡេក្រាមក្លែងក្លាយឈ្មោះ "**បណ្ណ/សៀវភៅការងារជនបរទេស**" (@sfcambodia_Chat) ដែលស្រដៀងនឹងឈ្មោះក្រុមតេឡេក្រាម "**បណ្ណ/សៀវភៅការងារជនបរទេស**" (https://t.me/foreignworkpermit) ផ្លូវការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាជិកចំនួនជាង ៦ ០០០នាក់ ជាមធ្យោបាយទាក់ទងជាមួយបុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីកម្មករនិយោជិត ដោយជនអនាមិកបានប្រឌិតព័ត៌មាន និងបង្គាប់ឱ្យបុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីកម្មករនិយោជិតបង់ប្រាក់ទៅកាន់លេខគណនីធនាគារ ឬ QR Code ផ្ទេរប្រាក់របស់ខ្លួន ដែលនាំឱ្យមានការខាតបង់ថវិការបស់និយោជក ឬសាមីកម្មករនិយោជិត។

ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ជូន ដូចខាងក្រោម៖

១. ក្រសួង មិនមានគោលការណ៍ឱ្យមន្ត្រីផ្សព្វផ្សាយលេខគណនីធនាគារផ្ទាល់ខ្លួនទៅបុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីកម្មករនិយោជិត នោះទេ ក្រៅពីមធ្យោបាយបង់ប្រាក់តាមប្រព័ន្ធ FWCMS (auto-reply@admin.fwcms.mlvt.gov.kh) របស់ក្រសួងនឹងផ្ញើទៅអ៊ីមែលរបស់អ្នកស្នើសុំ ឱ្យបង់ប្រាក់តាមរយៈធនាគារដៃគូដូចមាននៅក្នុងព័ត៌មានបង់ប្រាក់ (Payment Information)។ បន្ទាប់ពីទូទាត់រួច **ក្រសួងនឹងផ្ញើបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ដែលមាន QR Code ពិតប្រាកដដែលភ្ជាប់ទៅគេហទំព័រ** https://fwcms.mlvt.gov.kh/ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅអ៊ីមែលរបស់អ្នកស្នើសុំ។

របៀបនៃការបង់ប្រាក់តាមរយៈប្រព័ន្ធធនាគារដៃគូ៖

| កម្មវិធីទូរសព្ទដៃ (MOBILE APP) នៃ ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ (ABA BANK) | កម្មវិធីទូរសព្ទដៃ (MOBILE APP) នៃ ធនាគារ អេស៊ីលីដា (ACLEDA BANK) |
|---|---|
| - សេវាសាធារណៈ (Government Services)<br>- បណ្ណការងារជនបរទេស (Foreigner Work Permit)<br>- បញ្ចូលលេខកូដយោង (Reference No.)<br>ឧទាហរណ៍៖ A-xxxxxxxx | - សេវាសាធារណៈ (Public Services)<br>- បណ្ណការងារជនបរទេស (Foreign Worker Permit)<br>- បញ្ចូលលេខកូដយោង (Reference No.)<br>ឧទាហរណ៍៖ A-xxxxxxxx |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

២.ក្រសួង កំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីស្រាវជ្រាវ និងចាត់វិធានការតាមផ្លូវច្បាប់ ចំពោះជនប្រព្រឹត្តបទល្មើស។

៣.ក្នុងករណីសង្ស័យ ឬសាកសួរព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ប្រព័ន្ធ Hotline លេខ "**១២៨៦**" ឬ "**១២៩៧**" ឬ ក្រុមតេឡេក្រាមផ្លូវការ "**បណ្ណ/សៀវភៅការងារជនបរទេស**" (https://t.me/foreignworkpermit) ឬប្រអប់បណ្ដឹងអនាមិករបស់ក្រសួង (https://feedback.mlvt.gov.kh/feedback)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបុគ្គលិករដ្ឋបាល ឬតំណាងសហគ្រាស គ្រឹះស្ថាន ឬសាមីកម្មករនិយោជិត និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមបង្កើនការប្រុងប្រយ័ត្នចំពោះករណីឆបោកនេះ។

ថ្ងៃពុធ ១១កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២៥

"បណ្ណ/សៀវភៅការងារជនបរទេស"

"បណ្ដឹងអនាមិក"